**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ០២
ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៤
**<u>សាលដីកា</u>**
លេខៈ២១៣
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ………… ជាប្រធាន
២-លោក …………… ជាចៅក្រម
៣-លោក …………. ជាចៅក្រម
៤-លោក …………. ជាចៅក្រម
៥-លោក …………… ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា ………………

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម ………….. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៨០(ឈ) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៥៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាង :

ដើមចោទឈ្មោះដង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស តំណាងដោយប្រពន្ធ ឈ្មោះលឹម ស៊ីថា អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរកាត់ដេរ ទីលំនៅផ្ទះលេខ៧២$E_0$ ផ្លូវលេខ១២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

មានមេធាវីលោក……… ។

ចុងចម្លើយឈ្មោះចាន់ លី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រីអាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ៧២BE1 ផ្លូវលេខ១២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យបងថ្លៃឈ្មោះលឹម ហេង ។

មានមេធាវីលោក ………

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងសុំធ្វើរបង សុំឱ្យបញ្ឈប់ការលក់ដូររបស់ឈ្មោះចាន់ លី និងសុំប្តូរជណ្តើរផ្ទះរបស់ឈ្មោះចាន់ លី

បានឃើញបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះឈិត សារិទ្ធ (មេធាវីដើមចោទ) ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ១៨០(ឈ) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ២៦ ចុះថ្ងៃទី១៦ ខែមករាឆ្នាំ២០០៤ របស់លោកមេធាវី......... តំណាងឱ្យចាន់ លី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៨០(ឈ)ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ០២ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៤ របស់តុលាការ កំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៩-០៨-២០០២ របស់លោកជង ប្តឹងសុំធ្វើរបងផ្ទះ សុំឲ្យបញ្ឈប់ការ លក់ដូរ និងសុំប្តូរជណ្តើរផ្ទះរបស់ឈ្មោះចាន់ លី ដោយមូលហេតុថា : ឈ្មោះចាន់ លី បានធ្វើកិច្ចសន្យា ចំពោះមុខសមត្ថកិច្ចថា ឈប់លក់ដូរនៅផ្ទះរបស់នាងខ្ញុំ ប៉ុន្តែរហូតមកដល់បច្ចុប្បន្នឈ្មោះនេះនៅតែធ្វើការ លក់ដូរបន្តរហូត ដែលរំខានដល់ការស្នាក់នៅ និងសន្តិសុខ សុវត្ថិភាពរបស់គ្រួសារខ្លួន ព្រោះថា នៅពេល មានអ្នកផឹកស៊ីស្រវឹងឈ្លោះគ្នា បាញ់កាំភ្លើងចូលផ្ទះរបស់ខ្លួន ធ្វើឱ្យមានការតក់ស្លុតយ៉ាងខ្លាំង ដែលពុំអាច ឱ្យលក់ដូរបន្តទៅទៀតបានឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៥៦(ឋ)ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការក្រុង ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះជង ចុះថ្ងៃទី២៩-០៨-២០០២ ទុកជា ត្រឹមត្រូវតាមច្បាប់ ។

២-ទទួលស្គាល់លោក មេធាវីឈិត សារិទ្ធ តំណាងឱ្យដើមបណ្តឹង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលស្គាល់លោក មេធាវី......... តំណាងឱ្យចុងចម្លើយ ទុកជាត្រឹម ត្រូវតាមច្បាប់ ។

៤-ឱ្យដើមចោទឈ្មោះជា ង៉ា និងចុងចម្លើយឈ្មោះចាន់ លី សង់របងរួមគ្នា ដូចមានក្នុងលិខិត លេខ១៣២៧ ចុះថ្ងៃទី២៧-០៧-១៩៩៨ របស់មន្ទីររៀបចំក្រុង និងសំណង់ ។

៥-ឱ្យឈ្មោះជង ធ្វើរបងបាំង ស្របតាមកាំជណ្តើររហូតដល់របងដែលសង់ថ្មី ពីបង្កាន់ដៃខាងជើង មកខាងត្បូង១.២៥ម ។ ជណ្តើរនេះ ទុកជាសម្បត្តិរួមរបស់អ្នកនៅជាន់ខាងលើទាំងអស់គ្នា និងឱ្យឈ្មោះ ចាន់ លី បញ្ឈប់ការលក់ដូរមុខផ្ទះរបស់ឈ្មោះជង តទៅទៀត ។

៦-ឱ្យឈ្មោះជង យកសំភារៈទាំងអស់ ចេញពីមុខកាំជណ្តើរ ។សំណូមពរផ្សេងពីនេះ បដិសេធ ចោល ។

៧-បង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្មឹងចំនួន១៨០០៛ រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ និងរង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០៛ សរុប៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០រដែលដើមចោទ បានបង់ជាស្រេចតាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៨-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយសម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះលឹម ស៊ីថា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៥៦(ឋ) ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការ ក្រុងភ្នំពេញ ត្រង់ចំណុចដែលតុលាការបដិសេធការទាមទារប្រាក់ឈ្នួលដែលឈ្មោះចាន់លី បានលក់មុខផ្ទះកន្លងមករយៈពេល១១ឆ្នាំ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ របស់ឈ្មោះចាន់ លី និង លឹម ហេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៥៦(ឋ) ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៨០(ឈ) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧-០១-២០០៣ របស់ឈ្មោះលឹម ស៊ីថា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយទាស់និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧-០១-២០០៣ របស់ឈ្មោះចាន់ លី និងឈ្មោះលឹម ហេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៥៦(ឋ) ចុះថ្ងៃទី០៤-១២-២០០២ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៤-ប្រគល់សំយ៉ាបផ្ទះលេខ៧២BE1 និងដីចំហៀងផ្ទះ(ក្រោយសំយ៉ាប់)ខាងជើងដែលមានទទឹងខាងក្រោយប្រវែង១.៤៤ម ទទឹងកណ្តាលប្រវែង១.៧០ម ទទឹងខាងមុខប្រវែង១.៩០ម គិតពីជញ្ជាំងផ្ទះលេខ៧២BEo ទៅទល់នឹងរបងព្រំខាងជើង និងបណ្តោយ ចាប់ពីមុខបង្គន់រហូតដល់របងខាងមុខប្រវែង១៦.៨០ម ឱ្យទៅឈ្មោះចាន់ លី ដែលមានឈ្មោះលឹម ហេង ជាតំណាង កាន់កាប់គ្រប់គ្រង និងប្រើប្រាស់តទៅ ។

៥-បែងចែកដីមុខផ្ទះលេខ៧២BEo ជាពីរដោយប្រគល់ដីដែលមានទំហំទទឹងប្រវែង០១ម គិតចាប់ពីជញ្ជាំងខាងជើងនៃផ្ទះលេខ៧២BEo មកខាងត្បូង និងបណ្តោយប្រវែង៤៦០ម ត្រង់ទៅមុខទល់របងខាងមុខ ឱ្យទៅឈ្មោះចាន់ លី ដែលមានឈ្មោះលឹម ហេង ជាតំណាង កាន់កាប់គ្រប់គ្រង និងប្រើប្រាស់តទៅ ។

ដីចំណែកសល់ពីនេះ ប្រគល់ឱ្យឈ្មោះដង ដែលមានឈ្មោះលឹម ស៊ីថា ជា តំណាងកាន់កាប់គ្រប់គ្រង និងប្រើប្រាស់តទៅ ហើយឱ្យឈ្មោះចាន់ លី រុះរើជណ្តើរមកលើដី ដែលជាចំណែករបស់ខ្លួន ហើយទទួលបន្ទុកសោហ៊ុយចំណាយក្នុងការរុះរើជណ្តើរនេះផង ។

៦-អនុញ្ញាតឱ្យគូភាគីសាងសង់របងការពារដីរបស់ខ្លួនតាមចំណែករៀងៗខ្លួនបាន។

៧-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣.០០០៛ និងបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១% លើតម្លៃដីដែលប្រគល់ឱ្យចុងចម្លើយ និងឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១% លើតម្លៃដីដែលប្រគល់ឱ្យទៅដើមចោទ ។

៨-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៨-១១-២០០៣ ចំពោះមុខមេធាវីតំណាងគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥-១២-២០០៣ ចំពោះមុខមេធាវី តំណាងគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះឈិត សារិទ្ធ (មេធាវីដើមចោទ) ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៨០(ឈ)ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ២៦ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៤ របស់លោកមេធាវី ......... តំណាងឱ្យចាន់ លី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៨០(ឈ)ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី២០-០១-២០០៤ របស់ឈ្មោះលឹម ស៊ីថា ។

បានឃើញសារណាការពារ និងតបចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៤ របស់អ្នកស្រីចាន់លី និងលោកមេធាវី ......... ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : សាលដីការដ្ឋប្បវេណីលេខ១៨០(ឈ)ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះលឹម ស៊ីថា នាពេលសវនាការថា : នៅពីមុខផ្ទះរបស់ខ្លួន គេបានលក់ដូរពេញ ដែលជាហេតុនាំឱ្យមានការពិបាកចេញចូល ហើយនៅឆ្នាំ១៩៩១ ឈ្មោះចាន់ លី បានចាប់ផ្តើមលក់ លុះដល់ឆ្នាំ១៩៩២ ក៏មានទំនាស់ ហើយក៏ចាប់ដោះស្រាយរហូត ។

បានស្តាប់ចម្លើយរបស់ឈ្មោះលឹម ហេង នាពេលសវនាការថាៈ ការលក់ដូរពុំមានលក់នៅ លើដីទំនាស់ទេ ខ្លួនចាប់ផ្តើមលក់ពីម៉ោង៥ល្ងាច រហូតដល់ម៉ោង៨យប់ ហេតុនេះហើយខ្លួនសុំឱ្យតុលាការមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឈិត សារិទ្ធ ជាមេធាវីការពារឱ្យដើមចោទ និងជាម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងថា នៅឆ្នាំ១៩៨០ កូនក្តីខ្លួនបានមករស់នៅផ្ទះលេខ៧២AE1 ចំណែកចាន់ លី ក៏ដូច្នេះដែរ ។ លុះដល់ឆ្នាំ១៩៨៨ ឈ្មោះចាន់ លី បានលក់ផ្ទះឱ្យលោកគង់ ឆាយ បន្ទាប់មកទៀត លោកគង់ ឆាយ ក៏លក់មកឱ្យប្តីកូនក្តីខ្លួន ។ ចំណែកឈ្មោះចាន់ លី ពីមុនមិនមែន លក់សាច់អាំងចង្កាក់ និងស៊ុបផ្ទាំងដីនៅកន្លែងមានទំនាស់នេះឡើយ គឺលក់ពីមុខដីរបស់ឈ្មោះវ៉ក ហៀង ដែលមានកូនគ្រែមួយតូចទេ ។ លុះដល់អំឡុងឆ្នាំ១៩៩០ ឬ១៩៩១ លោកវ៉ក ហៀង បានរៀបចំសាងសង់ផ្ទះ ពេលនោះក៏ឈប់ឱ្យលក់ ហើយចាន់លី ក៏បានលក់ដូរមុខផ្ទះរបស់កូនក្តីខ្លួន ដោយគ្មានការអនុញ្ញាតិ ហើយដូរមុខរបរមកលក់ស៊ុប វិញ ដែលជាហេតុធ្វើឱ្យមានភាពរញ៉េរញ៉ៃ។ ហើយក៏មានការដោះស្រាយជាបន្តបន្ទាប់ ។ កូនក្តីខ្លួន មានសាក្សី និងឯកសារគ្រប់បែបយ៉ាងហេតុនេះ ខ្លួនសំណូមពរ

- សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល

-សុំលើកជណ្តើរមកដាក់កន្លែងផ្នែករ៉ងជាខាងផ្ទះឈ្មោះចាន់ លី

-សុំបែងចែកដីទីធ្លារួមមុខផ្ទះ ជាបីចំណែកស្មើៗគ្នា និងស៊ីធ្វើរបងឥដ្ឋខ័ណ្ឌតាមគំនូសពណ៌សូកូឡា

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក......... ជាមេធាវីការពារឱ្យចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងថា : នៅឆ្នាំ១៩៨០ កូនក្តីខ្លួនមានម្តាយឈ្មោះអុំ សុខ ជា មេគ្រួសារចូលមករស់នៅលុះឆ្នាំ១៩៨៣ អ្នកស្រីលឹម ស៊ីថា បានមកសុំលោកយាយនៅ បណ្តោះអាសន្ន រហូតបានកាន់កាប់មួយចំហៀងផ្ទះប៉ែកខាងត្បូងតែម្តង ឯពាក់កណ្តាលប៉ែកខាងជើង ត្រូវបានចាន់លី ជាអ្នកកាន់កាប់រួមទាំងដីយ៉ាប់ខាងជើងផ្ទះដែលមានបង្គន់នៅខាងក្រោយ ។ ចំណែកដីមុខផ្ទះចាប់ពីជើងសសរផ្ទះខាងជើងដល់ខាងត្បូង គឺប្រើប្រាស់រួមគ្នា រីឯដីចំហៀងផ្ទះខាងជើងក្រោមសំយ៉ាប់ផ្ទះភាគីកូនក្តីខ្លួនជាអ្នកកាន់កាប់ចេញចូលបង្គន់ដែលនៅខាងក្រោយតែម្នាក់ឯង បន្ទាប់មកកូនក្តីខ្លួនបានជួលដីខាងក្រោមផ្ទះ៧២BEo ចាប់ពីជើងសសរកណ្តាលផ្ទះឲ្យឈ្មោះគង់ ឆាយ តែក្រោយមកក៏កាត់ដីនេះឲ្យលោកគង់ ឆាយ នៅឆ្នាំ១៩៨៨ ឯដីចំហៀងផ្ទះក្រោមសំយ៉ាប់ខាងជើងជារបស់កូនក្តីខ្លួន ។ លុះដល់ឆ្នាំ១៩៨៩ គង់ឆាយ ក៏លក់ឲ្យជង ដោយរៀបចំបិទជញ្ជាំងផ្នែកខាងក្រោមជាផ្ទះ និងរៀបជញ្ជាំងខ័ណ្ឌដីឡូត៍ទំនេរមុខផ្ទះខាងត្បូងប្រើតែឯងចំណែកជណ្តើរចាស់ កូនក្តីខ្លួនរៀបចំតែម្នាក់ឯង ហើយសំយ៉ាប់ចំហៀងផ្ទះ ផ្នែកខាងជើង ក៏កូនក្តីខ្លួនបានការ លើកលែងតែត្រង់ចំណុចទី៥ ដោយមិនបាច់ធ្វិលតាមច្បាប់ដោយអនុគ្រោះ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើថា បណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៣ របស់មេធាវីដើមចោទ និង បណ្តឹងសាទុក្ខលេខ២៦ ចុះថ្ងៃទី១៦-០១-២០០៤ របស់មេធាវីចុងចម្លើយធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយធ្វើការបែងចែកដីចំហៀងផ្ទះទាំងអស់ និងដីមុខផ្ទះមានទទឹង១ម បណ្តោយ៤,៦០ម ឲ្យចុងចម្លើយដោយអាងហេតុថា ដីមុខផ្ទះជាដីប្រើប្រាស់រួម ហើយដំចំហៀងផ្ទះជាដីដែលចុងចម្លើយបានកាន់កាប់តែម្នាក់ឯងកន្លងមកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថាៈ

-ដីក្រោមផ្ទះលេខ៧២BE1 នេះចុងចម្លើយបានលក់ឲ្យឈ្មោះគង់ ឆាយ ហើយឈ្មោះគង់ ឆាយ បានលក់បន្តឲ្យដើមចោទ ។ ដីចំហៀងផ្ទះ គឺជាចំណីផ្ទះសម្រាប់សេវភាពរួម បើគ្មានការយល់ព្រមពីភាគីផ្សេងទេ ពុំអាចភាគីណាមួយយកធ្វើជាកម្មសិទ្ធិផ្តាច់មុខបានទេ នូវទ្រព្យអវិភាគនេះ ។

-ការបែងចែកដីចំហៀងឲ្យចុងចម្លើយតែម្នាក់ឯង មានលក្ខណៈគ្រប់គ្រាន់ជាមួយនឹងថ្លូវមុខផ្ទះ ដែលគប្បីប្រគល់ដីមុខផ្ទះនេះ ផ្តាច់មុខឲ្យដើមចោទហើយ ។

-យល់ឃើញថា សាលដីការរដ្ឋប្បវេណីលេខ១៨០(ឈ) ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី ចំពោះមុខគូភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ២០១ ចុះថ្ងៃទី១៦-១២-២០០៣ របស់មេធាវីដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលបណ្តឹងសាទុក្ខលេខ២៦ ចុះថ្ងៃទី១៦-០១-២០០៤ របស់អ្នកស្រីចាន់លី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសាធចោលដោយទុសនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈសាលដីការរដ្ឋប្បវេណីលេខ១៨០(ឈ) ចុះថ្ងៃទី០៥-១២-២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៤-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី០៦-០១-២០០៤ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៣៨០០០៛ ដែលដើមចោទបានបង់គឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ នៅសល់១៩០០០៛ ប្រគល់ឲ្យដើមចោទវិញ ហើយតម្រូវឲ្យចុងចម្លើយសងប្រាក់១៩០០០៛ នេះ ទៅចុងចម្លើយវិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ។